ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល
គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩
ក្នុងក្របខណ្ឌទូទាំងប្រទេស(គ.វ.ក-១៩)
លេខ ០១៥/២២ គ.វ.ក-១៩

ថ្ងៃសៅរ៍ ៦ កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ,ថ្ងៃទី ៨ ខែមករា ឆ្នាំ២០២២

# សេចក្តីជូនព័ត៌មាន
## ស្តីពី
## យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៤ សម្រាប់ក្រុមគោលដៅជម្រើសនៅរាជធានីភ្នំពេញ

គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស (គ.វ.ក-១៩) សូមគោរពជម្រាបជូនសាធារណជន មេត្តាជ្រាបថា **គ.វ.ក-១៩** នឹងផ្តល់ការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៤ ដោយប្រើវ៉ាក់សាំង Pfizer ជូនដល់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល ព្រឹទ្ធសភា រដ្ឋសភា ក្រុមគ្រូពេទ្យជួរមុខ(ទាំងរដ្ឋ និងឯកជន) មន្ត្រីរាជការ កងទ័ព នគរបាលជាតិ រហូតដល់អាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ច ជនវ័យចាស់ដែលមានអាយុចាប់ពី ៦០ឆ្នាំឡើង បុគ្គលិកស្ថានទូត អង្គការជាតិ អន្តរជាតិ អ្នកសារព័ត៌មាន និងសមាជិក សមាជិកា នៃសមាគមសសិល្បៈករកម្ពុជា ដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ ឬដូសជំរុញរួច ហើយមានគម្លាតចាប់ពី៤ខែឡើង បន្ទាប់ពីការចាក់វ៉ាក់សាំង កូវីដ-១៩ ដូសទី៣ ឬដូសជំរុញ ដូចខាងក្រោម៖

### ក. ការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៤ ជូនដល់មន្ត្រីរាជការស៊ីវិលថ្នាក់ជាតិ៖

ចំពោះថ្នាក់ដឹកនាំរាជរដ្ឋាភិបាល ព្រឹទ្ធសភា រដ្ឋសភាមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា ដែលកំពុងបម្រើការនៅថ្នាក់ជាតិ ដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ ឬដូសជំរុញរួច ហើយមានគម្លាតចាប់ពី៤ខែឡើង បន្ទាប់ពីការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ ឬដូសជំរុញ សូមអញ្ជើញទៅចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៤ ចាប់ពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០២២ នៅតាមមន្ទីរពេទ្យជាតិនានា ដែលមានទីតាំង កាលបរិច្ឆេទ និងពេលវេលា ដូចខាងក្រោម៖

### ១. មន្ទីរពេទ្យកាល់ម៉ែត និងមន្ទីរពេទ្យអង្គឌួង៖

- ចំពោះថ្នាក់ដឹកនាំរាជរដ្ឋាភិបាល ថ្នាក់ដឹកនាំព្រឹទ្ធសភា និងសមាជិកព្រឹទ្ធសភា ថ្នាក់ដឹកនាំរដ្ឋសភា និងសមាជិករដ្ឋសភា និងឥស្សរជនដែលមានតួនាទី ជាឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ ឬមានឋានៈស្មើ ហើយបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ ឬដូសជំរុញរួច ហើយមានគម្លាតចាប់ពី៤ខែឡើងបន្ទាប់ពីការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ ឬដូសជំរុញ សូមអញ្ជើញទៅចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៤ នៅមន្ទីរពេទ្យកាល់ម៉ែត។
- ចំពោះឥស្សរជនដែលជាអនុរដ្ឋលេខាធិការ អគ្គនាយក អគ្គនាយករង ឬមានឋានៈស្មើ ហើយបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ ឬដូសជំរុញរួច ហើយមានគម្លាតចាប់ពី៤ខែឡើងបន្ទាប់ពីការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ ឬដូសជំរុញ សូមអញ្ជើញទៅចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៤ នៅមន្ទីរពេទ្យព្រះអង្គឌួង។

ការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៤ ជូនដល់ក្រុមគោលដៅខាងលើ នឹងត្រូវរៀបចំតាមពេលវេលា និងកាលបរិច្ឆេទ ដូចខាងក្រោម៖



ទីស្តីការក្រសួងសុខាភិបាល ដីឡូត៍លេខ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ៖ (៨៥៥-២៣) ៨៨៥ ៩៧០/៨៨៤ ៩០៩

| ល.រ | ឈ្មោះក្រសួង និងស្ថាប័ន | កាលបរិច្ឆេទ | ពេលវេលា |
|---|---|---|---|
| ១ | -ឧត្តមក្រុមប្រឹក្សាអង្គចៅក្រម | ១៤ ដល់ ១៦ មករា ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ២ | -ក្រសួងព្រះបរមរាជវាំង | | |
| ៣ | -ព្រឹទ្ធសភា | | |
| ៤ | -ក្រុមប្រឹក្សាធម្មនុញ្ញ | | |
| ៥ | -រដ្ឋសភា | | |
| ៦ | -ក្រសួងសុខាភិបាល | ១៧ ដល់១៨ មករា២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ៧ | -ក្រសួងអប់រំ យុវជន និងកីឡា | | |
| ៨ | - សេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | |
| ៩ | -ធនាគារជាតិ នៃកម្ពុជា | | |
| ១០ | -ទីស្តីការគណៈរដ្ឋមន្ត្រី | ១៩ ដល់ ២០ មករា ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ១១ | -តុលាការកំពូល | | |
| ១២ | -សាលាឧទ្ធរណ៍ភ្នំពេញ | | |
| ១៣ | -ក្រសួងមហាផ្ទៃ | ២១ ដល់២២ មករា២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ១៤ | -ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | | |
| ១៥ | -ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | | |
| ១៦ | -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ២៣ ដល់២៤ មករា ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ១៧ | -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | | |
| ១៨ | -គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) | | |
| ១៩ | -ក្រសួងផែនការ | | |
| ២០ | -ក្រសួងអភិវឌ្ឍន៍ជនបទ | ២៥ ដល់២៦ មករា ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ២១ | -អាជ្ញាធរសេវាកម្មជាតិ | | |
| ២២ | -ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | | |
| ២៣ | -ក្រសួងសាធារណការ និងដឹកជញ្ជូន | | |
| ២៤ | -ក្រសួងបរិស្ថាន | | |
| ២៥ | -អង្គភាពប្រឆាំងអំពើពុករលួយ | ២៧ ដល់ ២៨ មករា២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ២៦ | -ក្រសួងកិច្ចការនារី | | |
| ២៧ | -ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | | |
| ២៨ | -ក្រសួងពាណិជ្ជកម្ម | | |
| ២៩ | -ក្រសួងមុខងារសាធារណៈ | | |
| ៣០ | -កាកបាទក្រហមកម្ពុជា | | |
| ៣១ | -ក្រសួងទេសចរណ៍ | ២៩ ដល់៣០ មករា ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ៣២ | -ក្រសួងព័ត៌មាន | | |
| ៣៣ | -ក្រសួងធម្មការ និងសាសនា | | |
| ៣៤ | -ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | | |



ទីស្តីការក្រសួងសុខាភិបាល ដីឡូត៍លេខ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរសព្ទ-ទូរសារ៖ (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

| | | | |
|---|---|---|---|
| ៣៥ | -ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | | |
| ៣៦ | -ក្រសួងធនធានទឹក និងឧតុនិយម | | |
| ៣៧ | -ក្រសួងយុត្តិធម៌ | | |
| ៣៨ | -ក្រសួងការងារ និងបណ្តុះបណ្តាល វិជ្ជាជីវៈ | ៣១ មករា ដល់០២ កុម្ភៈ ២០២២ | ម៉ោង០៨:00 ដល់១១:00<br>ម៉ោង១៤:00 ដល់១៧:00 |
| ៣៩ | -ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | | |
| ៤០ | -ក្រសួងរ៉ែ និងថាមពល | | |
| ៤១ | -អគ្គិសនីកម្ពុជា | | |
| ៤២ | -អាជ្ញាធរប្រេងកាត | | |
| ៤៣ | -អាកាសចរស៊ីវិល | | |
| ៤៤ | -អាជ្ញាធរផ្សេងៗ | | |

## ២. មន្ទីរពេទ្យកុមារជាតិ៖

មន្ទីរពេទ្យកុមារជាតិជាទីតាំងចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៤ ជូនមន្ត្រីរាជការចាប់ពីថ្នាក់ប្រធាននាយកដ្ឋានចុះ និងមន្ត្រីជាប់កិច្ចសន្យា នៃក្រសួង-ស្ថាប័ន ចំនួន៦ តាមកាលបរិច្ឆេទ និងពេលវេលាដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | ឈ្មោះក្រសួង និងស្ថាប័ន | កាលបរិច្ឆេទ | ពេលវេលា |
|---|---|---|---|
| ១ | -ឧត្តមក្រុមប្រឹក្សាចៅក្រម | ១៤ ដល់ ២០ មករា ឆ្នាំ២០២២ | ម៉ោង០៨:00 ដល់១១:00<br>ម៉ោង១៤:00 ដល់១៧:00 |
| ២ | -ក្រសួងសុខាភិបាល | | |
| ៣ | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ២១ ដល់ ២៦ មករា ឆ្នាំ២០២២ | ម៉ោង០៨:00 ដល់១១:00<br>ម៉ោង១៤:00 ដល់១៧:00 |
| ៤ | -ធនាគារជាតិ នៃកម្ពុជា | | |
| ៥ | -ក្រសួងអប់រំ យុវជន និងកីឡា | ២៧ មករា ដល់ ០២ កុម្ភៈ ឆ្នាំ២០២២ | ម៉ោង០៨:00 ដល់១១:00<br>ម៉ោង១៤:00 ដល់១៧:00 |
| ៦ | -ក្រសួងពាណិជ្ជកម្ម | | |

## ៣. មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត៖

មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ជាទីតាំងចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៤ ជូនមន្ត្រីរាជការចាប់ពីថ្នាក់ប្រធាននាយកដ្ឋានចុះ និងមន្ត្រីជាប់កិច្ចសន្យា នៃក្រសួង-ស្ថាប័ន ចំនួន២០ តាមកាលបរិច្ឆេទ និងពេលវេលាកំណត់ក្នុងតារាងខាងក្រោម៖

| ល.រ | ឈ្មោះក្រសួង និងស្ថាប័ន | កាលបរិច្ឆេទ | ពេលវេលា |
|---|---|---|---|
| ១ | -ក្រសួងព្រះបរមរាជវាំង | ១៤ ដល់ ១៨ មករា ឆ្នាំ២០២២ | ម៉ោង០៨:00 ដល់១១:00<br>ម៉ោង១៤:00 ដល់១៧:00 |
| ២ | -ព្រឹទ្ធសភា | | |
| ៣ | -ក្រុមប្រឹក្សាធម្មនុញ្ញ | | |
| ៤ | -រដ្ឋសភា | | |
| ៥ | -ទីស្តីការគណៈរដ្ឋមន្ត្រី | ១៩ ដល់ ២១ មករា ឆ្នាំ២០២២ | ម៉ោង០៨:00 ដល់១១:00<br>ម៉ោង១៤:00 ដល់១៧:00 |
| ៦ | -តុលាការកំពូល | | |
| ៧ | -សាលាឧទ្ធរណ៍ភ្នំពេញ | | |
| ៨ | -ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | ២២ ដល់ ២៤ មករា ឆ្នាំ២០២២ | ម៉ោង០៨:00 ដល់១១:00<br>ម៉ោង១៤:00 ដល់១៧:00 |
| ៩ | -ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | | |

| | | | |
|---|---|---|---|
| ១០ | -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ២៥ ដល់ ២៧ មករា ឆ្នាំ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ១១ | -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | | |
| ១២ | -គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) | | |
| ១៣ | -ក្រសួងផែនការ | ២៨ ដល់ ៣០ មករា ឆ្នាំ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ១៤ | -ក្រសួងអភិវឌ្ឍន៍ជនបទ | | |
| ១៥ | -អាជ្ញាធរសេវនកម្មជាតិ | | |
| ១៦ | -ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ៣១មករា ដល់ ០២កុម្ភៈឆ្នាំ ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ១៧ | -ក្រសួងសាធារណការ និងដឹកជញ្ជូន | ០៣ ដល់ ០៨ កុម្ភៈ ឆ្នាំ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ១៨ | -ក្រសួងបរិស្ថាន | | |
| ១៩ | -អង្គភាពប្រឆាំងអំពើពុករលួយ | | |
| ២០ | -ក្រសួងកិច្ចការនារី | | |

### ៤. មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក៖

មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក ជាទីតាំងចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៤ ជូនមន្ត្រីរាជការចាប់ពីថ្នាក់ប្រធាននាយកដ្ឋានចុះ និងមន្ត្រីជាប់កិច្ចសន្យា នៃក្រសួង-ស្ថាប័ន ចំនួន១៤ តាមកាលបរិច្ឆេទ និងពេលវេលាកំណត់ក្នុងតារាងខាងក្រោម៖

| ល.រ | ឈ្មោះក្រសួង និងស្ថាប័ន | កាលបរិច្ឆេទ | ពេលវេលា |
|---|---|---|---|
| ១ | -ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១៤ ដល់ ១៩ មករា ឆ្នាំ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ២ | -ក្រសួងមុខងារសាធារណៈ | | |
| ៣ | -កាកបាទក្រហមកម្ពុជា | | |
| ៤ | -ក្រសួងទេសចរណ៍ | ២០ ដល់ ២២ មករា ឆ្នាំ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ៥ | -ក្រសួងព័ត៌មាន | | |
| ៦ | -ក្រសួងយុត្តិធម៌ | ២៣ ដល់ ២៥ មករា ឆ្នាំ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ៧ | -ក្រសួងធម្មការ និងសាសនា | | |
| ៨ | -ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ២៦ ដល់ ៣០ មករា ឆ្នាំ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ៩ | -ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | | |
| ១០ | -ក្រសួងធនធានទឹក និងឧតុនិយម | ៣១ មករា ដល់ ០២ កុម្ភៈ ឆ្នាំ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ១១ | -ក្រសួងរ៉ែ និងថាមពល | | |
| ១២ | -ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ០៣ដល់ ០៦ កុម្ភៈ ឆ្នាំ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ១៣ | -អាកាសចរស៊ីវិល | | |
| ១៤ | -អាជ្ញាធរផ្សេងៗ | | |

## ខ. ការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៤ ជូនដល់មន្ត្រីអង្គការសហប្រជាជាតិ មន្ត្រី និងបុគ្គលិក ស្ថានទូតនានា មន្ត្រី និងបុគ្គលិកអង្គការជាតិ និងអន្តរជាតិ៖

ចំពោះមន្ត្រីអង្គការសហប្រជាជាតិ មន្ត្រី បុគ្គលិកស្ថានទូត ស្ថានកុងស៊ុល ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានា មន្ត្រី និងបុគ្គលិកអង្គការជាតិ អន្តរជាតិ និងដៃគូផ្សេងៗទៀត ដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ ឬដូសជំរុញរួច ហើយ

មានគម្លាតចាប់ពី៤ខែឡើងបន្ទាប់ពីការចាក់វ៉ាក់សាំងដូសទី៣ ឬដូសជំរុញ សូមអញ្ជើញទៅចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៤ នៅ **មន្ទីរពេទ្យកាល់ម៉ែត** តាមពេលវេលា និងកាលបរិច្ឆេទដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | ឈ្មោះអង្គភាព | កាលបរិច្ឆេទ | ពេលវេលា |
|---|---|---|---|
| ១ | -មន្ត្រីអង្គការសហប្រជាជាតិ មន្ត្រី និងបុគ្គលិកស្ថានទូត ស្ថានកុងស៊ុល និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានា | ០៧ ដល់ ០៨ កុម្ភៈ ឆ្នាំ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ២ | -មន្ត្រី និងបុគ្គលិកអង្គការជាតិ អន្តរជាតិ និងដៃគូផ្សេងៗទៀត | ០៩ ដល់ ១០ កុម្ភៈ ឆ្នាំ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |

**គ. ការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៤ ដល់អ្នកសារព័ត៌មាន និងសមាគមសិល្បៈករកម្ពុជាក្នុងរាជធានីភ្នំពេញ៖**

ចំពោះអ្នកសារព័ត៌មាន និងសមាគមសិល្បៈករកម្ពុជា ដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ ឬដូសជំរុញរួចហើយមានគម្លាតចាប់ពី៤ខែឡើងបន្ទាប់ពីការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ ឬដូសជំរុញ សូមអញ្ជើញទៅចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៤ នៅ **មន្ទីរព្រះអង្គឌួង** តាមពេលវេលា និងកាលបរិច្ឆេទដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | ឈ្មោះអង្គភាព | កាលបរិច្ឆេទ | ពេលវេលា |
|---|---|---|---|
| ១ | - អ្នកសារព័ត៌មានក្នុងរាជធានីភ្នំពេញ | ០៣ ដល់ ០៧ កុម្ភៈ ឆ្នាំ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ២ | - សមាគមសិល្បៈករកម្ពុជា | ០៨ ដល់ ១២ កុម្ភៈ ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |

**ឃ. ការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៤ ជូនដល់មន្ត្រីនគរបាលជាតិ នៅថ្នាក់ជាតិ៖**

ចំពោះមន្ត្រីនគរបាល ថ្នាក់ជាតិ ចាប់ពីថ្នាក់ប្រធាននាយកដ្ឋានចុះ និងមន្ត្រីជាប់កិច្ចសន្យា(នៅរាជធានីភ្នំពេញ) នៃក្រសួងមហាផ្ទៃ នឹងត្រូវរៀបចំចាត់ចែងការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៤ ជូនដោយក្រុមគ្រូពេទ្យ នៃមន្ទីរពេទ្យ១៦ ឧសភា របស់ក្រសួងមហាផ្ទៃតាមកាលបរិច្ឆេទ និងពេលវេលាកំណត់ក្នុងតារាងខាងក្រោម៖

| ល.រ | ឈ្មោះក្រសួង និងស្ថាប័ន | កាលបរិច្ឆេទ | ពេលវេលា |
|---|---|---|---|
| ១ | -ក្រសួងមហាផ្ទៃ | ១៤ ដល់ ២៧ មករា ឆ្នាំ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |

**ង. ការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៤ ជូនដល់ថ្នាក់ដឹកនាំនៃក្រសួងការពារជាតិ និងកងទ័ពនៅថ្នាក់ជាតិ៖**

ចំពោះ កងទ័ព គ្រួសារកងទ័ព និងអតីតយុទ្ធជន (នៅរាជធានីភ្នំពេញ) ដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ ឬដូសជំរុញរួច ហើយមានគម្លាតចាប់ពី៤ខែឡើងបន្ទាប់ពីការចាក់វ៉ាក់សាំងដូសទី៣ ឬដូសជំរុញ នឹងត្រូវរៀបចំចាត់ចែងចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៤ ដោយអនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្រសួងការពារជាតិ ដែលក្រសួងការពារជាតិនឹងចេញសេចក្តីជូនព័ត៌មានពីទីតាំង និងពេលវេលានៃការចាក់វ៉ាក់សាំងនេះជូនសាធារណជនជ្រាប។

**ច. ការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៤ ដោយរដ្ឋបាលរាជធានីភ្នំពេញ៖**

ចំពោះមន្ត្រីសុខាភិបាលជួរមុខ (ទាំងរដ្ឋ និងឯកជន) និងមន្ត្រីរាជការស៊ីវិល មន្ត្រីជាប់កិច្ចសន្យា ព្រមទាំងប្រជាពលរដ្ឋដែលមានអាយុចាប់ពី៦០ឆ្នាំឡើង ក្រោមឱវាទរដ្ឋបាលរាជធានីភ្នំពេញ ដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ ឬដូសជំរុញរួច ហើយមានគម្លាត ចាប់ពី៤ខែឡើងបន្ទាប់ពីការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ ឬដូសជំរុញ សូមអញ្ជើញទៅចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៤ ក្រោមការរៀបចំចាត់ចែង នៃរដ្ឋបាលរាជធានីភ្នំពេញ ហើយរដ្ឋបាលរាជធានីភ្នំពេញនឹងចេញសេចក្តីជូនព័ត៌មានផ្សព្វផ្សាយជូនសាធារណជនជ្រាបពីទីតាំង និងកាលបរិច្ឆេទ នៃការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៤នេះ។

## ឆ. ឯកសារត្រូវភ្ជាប់ជាមួយពេលទៅចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៤៖

ចំពោះក្រុមគោលដៅដូចបានជម្រាបជូនខាងលើ ហើយត្រូវមកទទួលការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៤ ត្រូវភ្ជាប់ជាមួយនូវឯកសារដូចខាងក្រោម៖

- ប័ណ្ណចាក់វ៉ាក់សាំងកូវីដ-១៩
- ប័ណ្ណសម្គាល់ខ្លួនមន្ត្រីរាជការ ឬប័ណ្ណសម្គាល់មន្ត្រីជាប់កិច្ចសន្យា (ចំពោះមន្ត្រីរាជការ ឬមន្ត្រីជាប់កិច្ចសន្យា)
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬឯកសារដែលប្រើប្រាស់ក្នុងការចុះឈ្មោះកាលពីចាក់វ៉ាក់សាំងដូសទី១

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ គ.វ.ក-១៩ សូមអំពាវនាវដល់ឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល ព្រឹទ្ធសភា រដ្ឋសភា ដែលក្រុមគ្រូពេទ្យជួរមុខ(ទាំងរដ្ឋ និងឯកជន) មន្ត្រីរាជការ កងទ័ព នគរបាលជាតិ រហូតដល់អាជ្ញាធរមូលដ្ឋាន សមត្ថកិច្ច បុគ្គលិកស្ថានទូត អង្គការជាតិ អន្តរជាតិ អ្នកសារព័ត៌មាន និងសមាជិក សមាជិកា នៃសមាគមសសិល្បៈករកម្ពុជា ជនវ័យចាស់ដែលមានអាយុចាប់ពី ៦០ឆ្នាំឡើង ដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ ឬដូសជំរុញរួច ហើយមានគម្លាតចាប់ពី៤ខែឡើង បន្ទាប់ពីការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ ឬដូសជំរុញ សូមអញ្ជើញទៅចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៤ ដើម្បីបង្កើនភាពស៊ាំទប់ទល់នឹងការឆ្លងរីករាលដាល នៃជំងឺកូវីដ-១៩ ជាពិសេសវីរុសបំប្លែងខ្លួនថ្មីប្រភេទដែលតា និងវីរុសបំប្លែងខ្លួនថ្មីប្រភេទអូមីក្រុង ដើម្បីបានវិលត្រឡប់ទៅដំណើរការជាប្រក្រតីនូវការរស់នៅ រួមទាំងសកម្មភាពសេដ្ឋកិច្ច និងសង្គមផ្សេងៗឡើងវិញ ក្នុងពេលខាងមុខនេះ។

ទន្ទឹមគ្នានេះដែរ គ.វ.ក-១៩ សូមគោរពជម្រាបជូនផងដែរថា ទោះបីជាបុគ្គលម្នាក់ៗបានទទួលការចាក់វ៉ាក់សាំងកូវីដ-១៩ រួចរាល់ហើយក្តី ក៏ត្រូវបន្តអនុវត្តនូវវិធានការ «៣ការពារ» (ពាក់ម៉ាស់ លាងដៃញឹកញាប់ និងរក្សាគម្លាតសុវត្ថិភាពបុគ្គលពី មួយម៉ែត្រកន្លះឡើងទៅ) និង «៣កុំ» (កុំទៅកន្លែងដែលមានមនុស្សច្រើនកុះករ កុំទៅកន្លែងដែលបិទជិតគ្មានខ្យល់ចេញចូល កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា កុំកៀកស្មាគ្នា) តាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក៏ដូចជាបន្តរួមគ្នាអនុវត្តតាមយុទ្ធនាការជាតិអប់រំក្រោមប្រធានបទ *«រួមគ្នាទទួលខុសត្រូវទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩»* ដើម្បីចូលរួមទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ នៅក្នុងសហគមន៍ នៃប្រទេសកម្ពុជា និងរក្សានិរន្តរភាព នៃការរស់នៅធម្មតា តាមប្រក្រតីភាពថ្មីក្នុងបរិបទនៃការប្រយុទ្ធនឹងជំងឺកូវីដ-១៩។

## ជ. កំណត់សំគាល់៖

ចំពោះក្រុមគោលដៅក្នុងជំរើសខាងលើ(ក្រុមគ្រូពេទ្យជួរមុខទាំងរដ្ឋ និងឯកជន មន្ត្រីរាជការ កងទ័ព គ្រួសារកងទ័ព នគរបាលជាតិ រហូតដល់អាជ្ញាធរមូលដ្ឋាន ជនវ័យចាស់ដែលមានអាយុចាប់ពី ៦០ឆ្នាំឡើង) នៅតាមបណ្តាខេត្តទាំង២៤ (ក្រៅពីរាជធានីភ្នំពេញ)សូមរង់ចាំប្រព័ន្ធត្រជាក់សំរាប់រក្សាទុកវ៉ាក់សាំងPfizerដែលនឹងមកដល់ក្នុងខែខាងមុខៗនេះជាមុនសិន (តាមការជូនដំណឹងរបស់UNICEF) ទើបអាចធ្វើការបែងចែកវ៉ាក់សាំងPfizerជូនបាន។



ទីស្តីការក្រសួងសុខាភិបាល ដីឡូត៍លេខ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ៖ (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

ប្រសិនបើបងប្អូនប្រជាពលរដ្ឋមានចម្ងល់ពាក់ព័ន្ធទៅនឹងការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៤ សូមទំនាក់ទំនងមកកាន់លេខទូរស័ព្ទខាងក្រោម៖

ក-ក្រុមការងារទំនាក់ទំនងសាធារណៈ / លេខាធិការដ្ឋាន៖

| | | |
|---|---|---|
| ០១២ ៩៨៩ ០៨៥ | ០១២ ៩១៦ ០៩៩ | ០១០ ២៣៣ ៥៨៨ |

ខ-ក្រុមការងារចុះឈ្មោះ និងប្រព័ន្ធព័ត៌មានវិទ្យា៖

| | | |
|---|---|---|
| ០១២ ៨៩៧ ០៤៣ | ០៦៨ ៩០៦ ៦៦៦ | ០១២ ៨៦៨ ៦៤០ |

គ-ក្រុមការងារសុវត្ថិភាពវ៉ាក់សាំង និងប្រាស្រ័យទាក់ទងហានិភ័យ៖

| | | |
|---|---|---|
| ០១២ ៨៨៧ ៣៨៧ | ០១២ ៨៣៦ ៨៦៨ | ០១២ ៨៩១ ៥២៧ |

**រដ្ឋលេខាធិការ និងជាប្រធានគណៈកម្មការចំពោះកិច្ច**
**ចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស(គ.ច.ក-១៩)**

**វេជ្ជ. ឱ វណ្ណឌីន**



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរសព្ទ-ទូរសារ៖ (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩